# ជំពូកទី ១

# សេចក្តីផ្តើម

Draft

Draft

# ជំពូកទី ១

# ស្ថានភាពទូទៅ

## ១.១ សេចក្តីផ្តើម

កម្ពុជាជាប្រទេសដែលសំបូរទៅដោយធនធានធម្មជាតិដ៏សំបូរបែបទាំងធនធានវប្បធម៌ និងធនធានធម្មជាតិ ដែលរួមមានធនធានសត្វព្រៃ ព្រៃឈើ និងធនធានរ៉ែ។ ធនធានទាំងនេះផ្តល់នូវសក្តានុពលយ៉ាងច្រើនក្នុងការចូលរួមដល់ការអភិវឌ្ឍន៍ប្រទេសជាតិ តាមរយៈការលើកទឹកចិត្តដល់វិនិយោគិនអោយចូលមកធ្វើការវិនិយោគ ដើម្បីកែច្នៃធនធានទាំងនោះ។

ការអភិវឌ្ឍន៍លើវិស័យនេះ ជាមធ្យោបាយក្នុងការបង្កើននូវផលិតកម្ម និងជាប្រភពស្រូបយកនូវកំលាំងពលកម្ម ព្រមទាំងបានផ្តល់នូវចំណេះដឹងថ្មីៗ និងបង្កើតការងារដល់ប្រជាជននៅជនបទ។ ជាងនេះទៅទៀតវានឹងរួមចំណែកផងដែលដល់ការបង្កើនចំណូលថវិការជាតិតាមរយៈការបង់ពន្ធជូនរដ្ឋ។

គោលនយោបាយ និងយុទ្ធសាស្ត្រចំបងរបស់រាជរដ្ឋាភិបាលគឺ ការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន និងជំរុញអោយមានកំណើនសេដ្ឋកិច្ចជាតិ។ គោលនយោបាយ យុទ្ធសាស្ត្រគាំទ្រ និងមធ្យោបាយផ្សេងៗបានដាក់ចេញដើម្បីជំរុញដល់ការរីកលូតលាស់សេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ដែលក្នុងនោះយុទ្ធសាស្ត្រក្នុងការទាក់ទាញវិនិយោគឯកជនក្នុង និងក្រៅប្រទេសក៏បានដើរតួនាទីរួមចំណែកយ៉ាងសំខាន់ដើម្បីសំរេចបាននូវទិសដៅខាងលើ។

ច្បាប់វិនិយោគរបស់ព្រះរាជាណាចក្រកម្ពុជា បានផ្តល់អោយវិនិយោគិននូវការលើកទឹកចិត្តយ៉ាងច្រើនស្ទើរគ្រប់វិស័យ ដែលនាំអោយមានការកើនឡើងយ៉ាងឆាប់រហ័សនៃការចូលវិនិយោគគ្រប់ផ្នែក ទាំងការវិនិយោគផលិតទំនិញនាំចេញ ការកសាងហេដ្ឋារចនាសម្ព័ន្ធ ការវិនិយោគផ្នែកទេសចរណ៍ និងការវិនិយោគលើវិស័យកសិកម្មក៏បានដើរតួនាទីយ៉ាងសំខាន់ណាស់ដែរ ក្នុងការចូលរួមអភិវឌ្ឍន៍ និងជំរុញកំណើនសេដ្ឋកិច្ចជាតិ។

ដោយផ្អែកលើលក្ខណៈអំណោយផលនានា ឱកាស និងឆ្លើយតបចំពោះតម្រូវការក្នុងការអភិវឌ្ឍន៍ប្រទេសជាតិក៏ដូចជាការអភិវឌ្ឍន៍ក្នុងតំបន់ ជាពិសេសដើម្បីចូលរួមចំណែកជួយរាជរដ្ឋាភិបាល សំរេចបាននូវទិសដៅដែលបានដាក់ចេញ ក្រុមហ៊ុន **ភូ យ៉ាង (ខេមបូឌា) PHU YANG (CAMBODIA) Co.,Ltd** បានពិនិត្យឃើញថាការវិនិយោគសំរាប់គម្រោងធ្វើអាជីវកម្មរ៉ែលោហៈ និងផែនការផលិតកម្ម ដែលជាការវិនិយោគមួយសមស្របបំផុតនៅលើស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ព្រោះការវិនិយោគនេះស្របជាមួយនឹងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលក៏ដូចជាផែនការ និងគោលដៅដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ចខេត្តផងដែរ។

ថ្វីត្បិតតែការវិនិយោគនេះអាចផ្តល់នូវគុណប្រយោជន៍ ចំពោះការលើកកម្ពស់ការអភិវឌ្ឍន៍សកម្មភាពសេដ្ឋកិច្ចខេត្តបាត់ដំបង និងសកម្មភាពសេដ្ឋកិច្ចជាតិក្តី ក៏ផលជាអវិជ្ជមានជាច្រើននឹងអាចកើតមានឡើងស្របគ្នាផងដែរ ដែលឥទ្ធិពលជាអវិជ្ជមានទាំងនេះ រួមមាន ការបាត់បង់ធនធានព្រៃឈើធម្មជាតិ ខូចខាតគុណភាពដី ការបាត់បង់សត្វព្រៃ ប៉ះពាល់ដល់មុខរបររបស់ប្រជាជន និងការបំពុលទឹកជាដើមនៅក្នុងតំបន់ បន្ទាប់ពីគំរោងធ្វើការឈូសឆាយ ដែរតម្រូវអោយក្រុមហ៊ុនត្រូវធ្វើការសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ ដើម្បីស្វែងយល់អំ

Draft

ពីហេតុប៉ះពាល់នានាព្រមជាមួយនឹងការលើកឡើងនូវវិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថានអវិជ្ជមានអោយដល់កម្រិតអប្បបរមា។

## ១.២ គោលបំណងនៃការសិក្សា

គោលបំណងនៃការសិក្សា លើការគម្រោងធ្វើអាជីវកម្មរ៉ែលោហៈ ដែលមានទីតាំងស្ថិតនៅតំបន់ភ្នំព្រឹក ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង របស់ក្រុមហ៊ុន **PHU YANG (CAMBODIA) Co., LTD.** នេះគឺចង់បង្ហាញពីគោលនយោបាយនៃការអភិវឌ្ឍន៍ប្រទេសកម្ពុជាអោយមានចីរភាព ពីព្រោះក្នុងដំណាក់កាលនេះ គឺជាដំណាក់កាលនៃការអភិវឌ្ឍន៍ ជាពិសេសការប្រកួតប្រជែងនៅលើទីផ្សារសេរីក្នុងតំបន់ និងការធ្វើសកលភាវូបនីយកម្ម។

ការសិក្សានេះ ធ្វើឡើងក្នុងគោលបំណង:

- ធានាការធ្វើវិនិយោគក្នុងរយៈពេលយូរអង្វែង
- យល់ដឹងពីធនធានបរិស្ថានដែលមានស្រាប់នៅក្នុងតំបន់
- វាយតំលៃលក្ខខ័ណ្ឌសេដ្ឋកិច្ច-សង្គម ដែលមានស្រាប់នៅជុំវិញទីតាំងគំរោង
- កំណត់សក្តានុពល និងកម្មូលហេតុនៃការប៉ះពាល់ទៅលើធនធានធម្មជាតិ និងសង្គមដំបូង ដោយសារសកម្មភាពនៃការធ្វើវិនិយោគរបស់ក្រុមហ៊ុន
- កំណត់វិធានការទប់ស្កាត់ ឬកាត់បន្ថយរាល់ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន ដែលកើតមានឡើងពីសកម្មភាពគំរោងអោយដល់កម្រិតអប្បបរមា
- រៀបចំផែនការគ្រប់គ្រងបរិស្ថានសំរាប់គំរោងអភិវឌ្ឍន៍នេះ
- ដកស្រង់អនុសាសន៍ល្អៗពីស្ថាប័នពាក់ព័ន្ធលើវិធានការពាររយៈពេលខ្លី-វែង និងលទ្ធផល ឬឥទ្ធិពលមិនល្អរបស់គំរោងដែលបានស្នើសុំ
- ចូលរួមចំណែកក្នុងការអភិវឌ្ឍន៍ប្រទេសជាតិប្រកបដោយនិរន្តរភាព។ ក្នុងគោលបំណងបន្ទាប់មកទៀតគឺលើការអនុវត្តច្បាប់ អនុក្រឹត្យ ប្រកាស គោលការណ៍ណែនាំនានា របស់រាជរដ្ឋាភិបាល និងគោរពតាមការណែនាំរបស់មន្រ្តីមានសមត្ថកិច្ច អ្នកដែលពាក់ព័ន្ធនានា និងចង់បង្ហាញពីការចូលរួមរបស់សាធារណៈជន ជាពិសេសប្រជាពលរដ្ឋ ដែលរងនូវការប៉ះពាល់ពីសកម្មភាពគំរោង។

## ១.៣ វិធីសាស្ត្រនៃការសិក្សា

### ១.៣.១ ការរៀបចំគំរោងនៃការសិក្សា

គំរោងនៃការសិក្សាស្រាវជ្រាវមានសារៈសំខាន់ណាស់ ក្នុងការរៀបចំនូវរបាយការណ៍នេះ ព្រោះវាជាផ្លូវទៅរកការដំណោះស្រាយនៃចំណោទបញ្ហា។ ការសិក្សាតាមដំណាក់កាលមួយចំនួនដែលត្រូវបានរៀបចំសំរាប់ដំណើរការ និងអភិវឌ្ឍន៍គំរោងនៃការសិក្សាស្រាវជ្រាវនេះ។

ដំណាក់កាលទាំងនេះរួមមាន:

១-ការសិក្សាពីការបង្កើតគំរោង ដោយចាប់ផ្តើមចេញពីការកំណត់បទដ្ឋានច្បាប់ និងបច្ចេកទេស

២-ការសិក្សាពីគោលបំណងដែលផ្តោះទៅរកកំណត់នូវប្រភេទ និងប្រភពព័ត៌មាន រួមផ្សំវិធីសាស្ត្រក្នុងការសិក្សា

៣-សិក្សា និងប្រមូលឯកសារ និងទិន្នន័យពាក់ព័ន្ធនឹងគំរោងនៅតាមក្រសួង/ស្ថាប័ននានា

៤-ការរៀបចំកម្រងសំនួរដែរទាក់ទងនឹងគំរោង

៥-ការរៀបចំក្រុមការងារចុះសិក្សាស្រាវជ្រាវទិន្នន័យ

៦-ការចុះប្រមូលឯកសារ និងទិន្នន័យដែលទាក់ទងនឹងគំរោងនៅក្នុង និងជុំវិញទីតាំងគំរោង

៧-ការវិភាគទិន្នន័យ

៨-របកគំហើញនៃការសិក្សា

៩-ការសន្និដ្ឋាន និងអនុសាសន៍

### ១.៣.២ ការរៀបចំក្រុមការងារចុះសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវ និងវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ លើគំរោងវិនិយោគធ្វើអាជីវកម្មរ៉ែលោហៈនេះ ត្រូវបានរៀបចំឡើងដោយក្រុមសិក្សារបស់ក្រុមហ៊ុន **ហ្គ្រីន អ៊ីនវាយរិនមិន គ្រុប ខូ អិល ធី** (Green Environment Group Co., Ltd.) ដែលជាក្រុមសិក្សាមានសមាសភាពមកពីជំនាញចំរុះ ហើយក្រុមការងារវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គម មានចំនួន ០៦នាក់ដូចមានរាយនាមខាងក្រោម:

១.លោក ហៃ ដាលីណូ ប្រធានក្រុម ជំនាញវិទ្យាសាស្ត្របរិស្ថាន

២.លោក អ៊ឹង បូនីន អនុប្រធានក្រុម ជំនាញសេដ្ឋកិច្ចអភិវឌ្ឍន៍

៣.កញ្ញា អ៊ុន លក្ខិណា សមាជិក ជំនាញសេដ្ឋកិច្ចកសិកម្ម និងអភិវឌ្ឍន៍ជនបទ

៤.លោក ហាក់ សំបូរ សមាជិក ជំនាញវិទ្យាសាស្ត្រព្រៃឈើ

៥.លោក ជា សុខអ៊ីម សមាជិក ជំនាញរៀបចំដែនដី និងរដ្ឋបាលដីធ្លី

៦.លោក ម៉ុក យ៉ាវ៉ាន់ សមាជិក ជំនាញវិទ្យាសាស្ត្របរិស្ថាន

Draft

### ១.៣.៣ ការកំណត់ទីតាំងនៃការសិក្សា

ការសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមនេះនឹងផ្តោតទៅលើទីតាំងដែលក្រុមហ៊ុនវិនិយោគស្នើសុំលើទំហំ ០៤ គីឡូម៉ែត្រក្រឡា ស្មើនឹង ៤០០ ហិកតា ស្ថិតនៅតំបន់ភ្នំព្រឹក ក្នុងភូមិសាស្ត្រស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ហេតុនេះទីតាំងដែលពាក់ព័ន្ធក្នុងការសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមនេះរួមមាន:

តារាង ១-១ ទីតាំងនៃការសិក្សា

| ខេត្ត | ស្រុក | ឃុំ | ភូមិ |
|---|---|---|---|
| បាត់ដំបង | ភ្នំព្រឹក | ភ្នំព្រឹក | ភ្នំព្រឹក |

### ១.៣.៤ ប្រភព និងវិធីសាស្ត្រនៃការប្រមូល និងការវិភាគ-វាយតំលៃ

ក.ប្រភព និងការប្រមូលទិន្នន័យ

ការសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមលើគំរោងនេះធ្វើឡើងដោយផ្អែកលើប្រភពព័ត៌មាន២

ប្រភេទ: ព័ត៌មានបន្ទាប់បន្សំ និងព័ត៌មានបឋម។

ក.១ ព័ត៌មានបន្ទាប់បន្សំ

ប្រភពព័ត៌មានបន្ទាប់បន្សំត្រូវបានប្រមូលពី តាមស្ថាប័នពាក់ព័ន្ធនានា ដែលរួមមានឯកសារ:

-ព្រះរាជក្រឹត្យ និងច្បាប់: (១) ច្បាប់ស្តីអំពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ (២) ច្បាប់ភូមិបាល (៣) ច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ (៤) ច្បាប់ស្តីពីព្រៃឈើ (៥) ច្បាប់ស្តីពីជលផល (៦)ច្បាប់គ្រប់គ្រងធនធានទឹក (៧) ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ (៨) ច្បាប់ និងបទបញ្ញត្តិស្តីពីការវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។

-អនុក្រឹត្យ: (១) អនុក្រឹត្យស្តីពីកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន (២) អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលទឹក (៣) អនុក្រឹត្យស្តីពីការគ្រប់គ្រងសំណល់រឹង និង(៤) អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំលេង។

-ព័ត៌មានស្តីអំពីធនធានរូបសាស្ត្រដែលបកស្រាយអំពីប្រព័ន្ធផ្លូវទឹក ប្រភេទដី រយៈកំពស់ ចំណាត់ថ្នាក់ទីជំរាល និងអាកាសធាតុ រួមមាន: (១) ឯកសារស្តីពីប្រភេទដី របស់លោក Charles D.Crocker ឆ្នាំ១៩៦២ (២) ផែនទីភូមិសាស្ត្រ (Topography Map) របស់ភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន(JICA) ឆ្នាំ២០០២ ក្នុងមាត្រដ្ឋាន ១/៥០០.០០០ និង ១/១០០.០០០ (៣)ផែនទីស្តីពីភូគព្ភសាស្ត្ររបស់ភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) ឆ្នាំ២០០២ (៤) ទិន្នន័យអាកាសធាតុ ខេត្តបាត់ដំបង បានពីនាយកដ្ឋានឧតុនិយមឆ្នាំ២០១០។

-ព័ត៌មានស្តីអំពីធនធានជីវសាស្ត្រក្នុងតំបន់រួមមាន:(១) ឯកសារស្តីពីស្ថានភាពធនធានព្រៃឈើ ផ្អែកលើផែនទីគម្របព្រៃឈើឆ្នាំ ២០០២ និងគម្របព្រៃឆ្នាំ២០០៦ របស់រដ្ឋបាលព្រៃឈើនៃព្រះរាជាណាចក្រកម្ពុជា និងរូបភាពថតពីលើអាកាស។

-ព័ត៌មានស្តីពីធនធានសង្គម និងសេដ្ឋកិច្ច ដែលមានស្រាប់នៅក្នុងសៀវភៅទិន្នន័យភូមិ និងទិន្នន័យឃុំសំរាប់ការកសាងផែនការអភិវឌ្ឍន៍ឃុំ ដោយរួមមាន ស្ថិតិចំនួនប្រជាជន ការផ្គត់ផ្គង់ទឹក និងអនាម័យ ស្ថិតិលំនៅដ្ឋាន ចំណូល និង ចំណាកស្រុក មុខរបរ និងប្រាក់ចំណូល សេវាកម្មសុខភាព សិក្សាធិការ ការប្រើប្រាស់ដីតាមបែបប្រពៃណី ជនជាតិដើមភាគតិច និងជំនឿសាសនាជាដើម។

-ឯកសារបានពីក្រុមហ៊ុនអនុវត្តគំរោងរួមមាន: សៀវភៅផែនការមេរបស់ក្រុមហ៊ុន អាជ្ញាប័ណ្ណនានាចេញពីស្ថាប័នពាក់ព័ន្ធ សៀវភៅលក្ខន្តិកៈរបស់ក្រុមហ៊ុន និងកិច្ចសន្យារបស់ក្រុមហ៊ុនជាមួយនឹងក្រសួងបរិស្ថាន។

ក.២ ព័ត៌មានបឋម

ប្រភពព័ត៌មានបឋម ត្រូវបានចុះប្រមូលដោយផ្ទាល់ ដោយក្រុមសិក្សាស្រាវជ្រាវ ដែលក្នុងនោះរួមមាន:

- ព័ត៌មានស្តីពីស្ថានភាពធនធានរូបសាស្ត្រ និងជីវសាស្ត្ររួមមាន: (១) ការពិនិត្យអំពីប្រភពទឹក និងគុណភាពទឹក តាមរយៈការចុះយកសំណាកទឹកមកធ្វើការវិភាគនៅក្នុងមន្ទីរពិសោធន៍របស់ក្រសួងបរិស្ថាន (២) ការចុះអង្កេតព្រៃឈើ (៣) ការសាកសួរប្រជាជនក្នុងតំបន់អំពីប្រភេទឈើ និងសត្វនៅក្នុងតំបន់ដែលអម ដោយបញ្ជីឈ្មោះសត្វ និងសៀវភៅប្រភេទត្រីទឹកសាបសំខាន់ៗនៅប្រទេសកម្ពុជា សៀវភៅថនិកសត្វនៃប្រទេសកម្ពុជា រៀបរៀងដោយម៉ែន សូរិយន់, សួន ផល្លា, ស៊ិន ប៉ូលីន និង Joe Walston

(២០០៨) និងសៀវភៅសត្វស្លាបនៃប្រទេសកម្ពុជា រៀបរៀងដោយ គាន់ សេដ្ឋា និង កូលីន ភូល(២០០៣)។

- ព័ត៌មានស្តីពីស្ថានភាពធនធានសេដ្ឋកិច្ច-សង្គម ដោយផ្តោតសំខាន់អំពីៈ មុខរបរ និងប្រាក់ចំណូលរបស់គ្រួសារនៅក្នុងតំបន់មួយៗ ដោយប្រើប្រាស់នូវកំរងសំណួរ។ វិធីសាស្ត្រក្នុងការប្រមូលព័ត៌មានៈ
  - ការយកសំណាកគឺជ្រើសយកតែប្រជាជន ដែលមានដីលំនៅដ្ឋាន និងដីស្រែ-ចំការស្ថិតនៅលើដី ០៤គីឡូម៉ែត្រក្រឡា (៤០០ហិកតា) ដែលក្រុមហ៊ុន Phu Yang (Cambodia) Co.,Ltd បានទទួលអាជ្ញាប័ណ្ណធ្វើអាជីវកម្មរ៉ែ លោហៈប៉ុណ្ណោះ ដែលមានចំនួន ៥៧គ្រួសារ។
  - ប្រើប្រាស់បញ្ជីសំនួរដែលបានរៀបចំរួច ដើម្បីសម្ភាសន៍យកព័ត៌មាន។

. (១) តំបន់ការពារនានា និងដីពាក់ព័ន្ធរវាងប្រជាជន និងគំរោងអភិវឌ្ឍន៍ (២) មតិយោបល់របស់ប្រជាជនចំពោះគំរោងអភិវឌ្ឍន៍ និងសំណូមពរ ដោយក្នុងនោះយើងនឹងប្រើប្រាស់នូវវិធីសាស្ត្រវាយតំលៃជនបទដោយរហ័ស (RRA) ដោយរួមមានវិធីសាស្ត្រ (ក).ការពិភាក្សាជាក្រុមដោយមានការជ្រើសរើសសំណាកដោយចៃដន្យ (ខ)-ការគូរផែនទីក្នុងតំបន់ និង (គ)-ការរៀបចំប្រតិទិនរដូវកាល។

. មតិយោបល់របស់អាជ្ញាធរមូលដ្ឋានមាន (១) អាជ្ញាធរខេត្តបាត់ដំបង (២) អាជ្ញាធរស្រុកភ្នំព្រឹក (៣) អាជ្ញាធរឃុំភ្នំព្រឹក(ភូមិភ្នំព្រឹក) និងវិធីសាស្ត្រដោះស្រាយចំពោះហេតុប៉ះពាល់ទាំងអស់នោះ ដោយប្រើប្រាស់នូវបញ្ជីសំណួរ និងផែនទីបង្ហាញទីតាំង។

. មតិយោបល់របស់ស្ថាប័នជំនាញពាក់ព័ន្ធមាន (១) មន្ទីរបរិស្ថាន (២) មន្ទីរកសិកម្ម (៣)មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត (៤) ខណ្ឌរដ្ឋបាលព្រៃឈើ (៥)ខណ្ឌរដ្ឋបាលជលផល (៦)មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ។ ដើម្បីស្វែងយល់អំពីការប៉ះពាល់របស់គំរោង និងវិធីសាស្ត្រដោះស្រាយចំពោះហេតុប៉ះពាល់ទាំងអស់នោះដោយប្រើប្រាស់នូវបញ្ជីសំណួរ និងផែនទីបង្ហាញទីតាំង

**ខ.ការវិភាគ-វាយតំលៃ**

ក្នុងការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមលើគំរោងវិនិយោគនេះ ក្រុមសិក្សានឹងប្រើប្រាស់នូវវិធីសាស្ត្រវិភាគបែបគុណភាព និងបរិមាណ។ ចំពោះការវាយតំលៃអំពីហេតុប៉ះពាល់បរិស្ថាននឹងប្រើប្រាស់នូវវិធីសាស្ត្រវាយតំលៃតាម (១) បញ្ជីផ្ទៀងផ្ទាត់ (Checklist) របស់ក្រសួងបរិស្ថាន ដើម្បីកំណត់នូវហេតុប៉ះពាល់អវិជ្ជមានទាំងឡាយ និង (២) វិធីសាស្ត្រផ្អែកតាមផែនទី ដោយផ្អែកតាមព័ត៌មានភូមិសាស្ត្រ (GIS) ដើម្បីបង្ហាញនូវតំបន់នានាដែលនឹងមានការផ្លាស់ប្តូរនៅពេលមានវត្តមាននៃគំរោង ដែលនឹងបង្កនូវហេតុប៉ះពាល់អវិជ្ជមានចំពោះ ធនធានបរិស្ថាន និងសង្គម (៣) ការប្រើប្រាស់កម្មវិធី SPSS, Excel ដើម្បីវិភាគទិន្នន័យសេដ្ឋកិច្ច-សង្គម។

## ១.៤ ដែនកំណត់នៃការសិក្សា

គំរោងវិនិយោគរបស់ក្រុមហ៊ុន ភូ យ៉ាង (ខេមបូឌា) **PHU YANG (CAMBODIA) Co.,Ltd** ស្ថិតនៅលើផ្ទៃដីទំហំ ៤០០ ហិកតាដែលស្ថិតក្នុងភូមិសាស្ត្រស្រុកភ្នំព្រឹក ខេត្តបាត់ដំបង។

ចំណែកការសិក្សាអំពីធនធានសេដ្ឋកិច្ច-សង្គម ក្រុមសិក្សានឹងធ្វើឡើងតែជាមួយនឹងអាជ្ញាធរថ្នាក់ខេត្ត និងស្ថាប័នជំនាញពាក់ព័ន្ធរបស់ខេត្តបាត់ដំបងដែលទីតាំងនៃគំរោងស្ថិតនៅប៉ុណ្ណោះ។

តារាង ១-២ ការប្រមូលព័ត៌មានសំខាន់ៗសម្រាប់ការសិក្សា

| គោលបំណង | តម្រូវការព័ត៌មាន | | ប្រភព | ប្រភេទទិន្នន័យ |
|---|---|---|---|---|
| ស្វែងយល់ពីធនធានបរិស្ថានដែលមានស្រាប់នៅក្នុងតំបន់ | ឋានលេខា | -សណ្ឋានដី (រយៈកម្ពស់ កម្រិតចំណោត់ថ្នាក់ទីជំរាល ទិដ្ឋភាពទីជំរាល) | -JICA datasheet 2002 | ទិន្នន័យបន្ទាប់បន្សំ |
| | | -ប្រភេទដី | -Charles D.Crocker 1962 | |
| | ភូគព្ភសាស្ត្រ | | -JICA datasheet 2002 | ទិន្នន័យបន្ទាប់បន្សំ |
| | អាកាសធាតុ | -សីតុណ្ហភាព<br>-កម្រិតទឹកភ្លៀង<br>-សំណើមបរិយាកាស<br>-កំដៅថ្ងៃ | -នាយកដ្ឋានឧតុនិយម ២០០៩<br>-សៀវភៅផែនការមេរបស់គំរោង | ទិន្នន័យបន្ទាប់បន្សំ |
| | ជលសាស្ត្រ | ស្ថានភាពផ្លូវទឹកលើដី | -ចុះអង្កេតផ្ទាល់នៅតំបន់សិក្សា<br>-ការសិក្សាលើផែនទី Topo map(1/100.000) | ទិន្នន័យបន្ទាប់បន្សំ<br>ទិន្នន័យបឋម |
| | | គុណភាពទឹកលើដី | -យកសំណាកទឹកនៅតំបន់សិក្សាចូលមន្ទីរពិសោធន៍ ក្រសួងបរិស្ថាន | ទិន្នន័យបឋម |
| | ធនធានព្រៃឈើ និងសត្វព្រៃ | | -ចុះអង្កេតផ្ទាល់នៅតំបន់សិក្សា<br>-សាកសួរប្រជាពលរដ្ឋក្នុងតំបន់ពីស្ថានភាពធនធានព្រៃឈើ និងសត្វព្រៃ<br>-ធ្វើការចុះអង្កេតព្រៃឈើ និងសត្វព្រៃ ដោយក្រុមសិក្សា | ទិន្នន័យបឋម |
| | ធនធានសេដ្ឋកិច្ច-សង្គម | | -ចុះអង្កេតផ្ទាល់ក្នុងតំបន់សិក្សា<br>-សម្ភាសន៍ប្រជាជនក្នុងភូមិពាក់ព័ន្ធ<br>ឬភូមិដែលទទួល | ទិន្នន័យបឋម |

Draft

| | | | |
|---|---|---|---|
| | | រងការប៉ះពាល់<br>-ប្រមូលព័ត៌មានដែលពាក់ព័ន្ធរួមមានស្ថិតិប្រជាជន | |
| ធ្វើការពិនិត្យលើកដំបូងទៅលើការប៉ះពាល់ដោយផ្ទាល់ឬប្រយោលចំពោះតំបន់តំរោងអភិវឌ្ឍន៍ និងតំបន់ជុំវិញតំរោង | ហេតុប៉ះពាល់អវិជ្ជមានពីតំរោងចំពោះសង្គម និងបរិស្ថាន | -សម្ភាសន៍ប្រជាជនពីការប៉ះពាល់ដែលអាចកើតមានពីតំរោង<br>-ចុះអង្កេតផ្ទាល់នៅក្នុងទីតាំងដែលរងនូវការប៉ះពាល់<br>-រៀបចំក្រុមពិភាក្សាជាមួយប្រជាជន និងអាជ្ញាធរមូលដ្ឋានយកមតិយោបល់និង សំណូមពររបស់ពួកគាត់ទៅលើតំរោង | ទិន្នន័យបឋម |

Draft

រូបភាព ១-១ វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ




Draft

ប្រភព: Green Environment Group Co., Ltd. ២០១២